<u>សេចក្តីប្រកាសព័ត៌មានស្តីពី</u>

កិច្ចប្រជុំលើក ទី១២ នៃក្រុមប្រឹក្សាស្តង់ដារជាតិ នៅសណ្ឋាគារ SUNWAY រាជធានីភ្នំពេញ




កិច្ចប្រជុំលើកទី១២ នៃក្រុមប្រឹក្សាស្តង់ដារជាតិ ត្រូវបានរៀបចំឡើង នៅព្រឹកថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤ ក្រោមអធិបតីភាព ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ នៅសណ្ឋាគារ SUNWAY រាជធានីភ្នំពេញ ។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងដោយវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយសហការ ឧបត្ថម្ភពីគម្រោងពង្រឹងសមត្ថភាពវិទ្យាស្ថានដ្ឋានស្តង់ដារកម្ពុជា ដោយមានការចូលរួមពីសមាជិករបស់ក្រុមប្រឹក្សាស្តង់ដារជាតិ ដែលតំណាងឱ្យក្រសួង ស្ថាប័ន និងសាកលវិទ្យាល័យសរុប ចំនួន២១រូប ។

-ការរៀបចំកិច្ចប្រជុំនេះឡើង ក្នុងគោលបំណងដើម្បី :**ទី១-សរុបរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់ ក្រុមប្រឹក្សាស្តង់ដារជាតិលើកទី១១ :** របាយការណ៍បានលើកឡើងពីលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាស្តង់ដារជាតិលើកទី១១ កាលពីថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៤ នៅវិទ្យាស្ថានស្តង់ដារកម្ពុជា ដែលបានសម្រេចអនុម័តស្តង់ដារភូមិច ចំនួន ៣៣១ និងស្តង់ដារអន្តរជាតិ ISO ចំនួន ០៤ ជាស្តង់ដារជាតិសម្រាប់ប្រើប្រាស់ជាទូទៅ ព្រមទាំងអនុម័តស្តង់ដារជាតិចំនួន ១០ ជាស្តង់ដារបញ្ជាផងដែរ ។ **ទី២:ស្តាប់សេចក្តីរាយការណ៍សកម្មភាពរបស់គណៈកម្មការបច្ចេកទេស ទី២ ទី៣ និងទី៤ :** ក្នុងរបាយការណ៍បានបញ្ជាក់ថា: គណៈកម្មការបច្ចេកទេសទាំង៣ ខាងលើ ដែលទាក់ទង និងសារធាតុគីមី ម្ហូបអាហារ និងបន្លែផ្លែឈើ បានរៀបចំកិច្ចប្រជុំជាច្រើនលើកច្រើនសារ ដើម្បីប្រជុំពិនិត្យពិភាក្សា និងកែសម្រួលលើស្តង់ដារអន្តរជាតិចំនួន០៨ ហើយបានបញ្ចូលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្តង់ដារជាតិលើកទី១២ នេះ ដើម្បីសុំការអនុម័តស្តង់ដារអន្តរជាតិទាំងនេះ ជាស្តង់ដារជាតិ ។ **ទី៣:សុំការអនុម័តសេចក្តីព្រាងស្តង់ដារចំនួន០៨ ខាងលើ ជាស្តង់ដារជាតិ :** យោងតាមការពិភាក្សាយ៉ាងផុលផុសក្រោមកិច្ចសម្របសម្រួលរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ សេចក្តីព្រាងស្តង់ដារចំនួន៨ ទាក់ទងនិងផលិតផល **ម្សៅពោត ការ៉េម ប្រហិតសាច់ ចង់ផ្កាស្ទីក គុយទាវស្ងួត ទឹកជ្រលក់ប៉េងប៉ោះរាវ គ្រាប់ពោត**

**និងគ្រាប់សណ្តែកសៀង** អង្គប្រជុំបានអនុម័តសម្រេចយកធ្វើជាស្តង់ដារជាតិ សម្រាប់ក្រុមហ៊ុន សហគ្រាស រោងចក្រ សិប្បកម្ម អង្គភាពធ្វើតេស្ត អង្គភាពអធិការកិច្ច និងការត្រួតពិនិត្យការនាំចេញ–នាំចូល អនុវត្តនៅក្នុងទិសដៅពង្រឹងគុណភាព និងសុវត្ថិភាពផលិតផលម្ហូបអហារ នៅកម្ពុជា ។








មានប្រសាសន៍បិទកិច្ចប្រជុំ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងនៃសមាជិកក្រុមប្រឹក្សាស្តង់ដារជាតិទាំងអស់ ក្នុងការបំពេញភារកិច្ចស្នូលរៀងៗខ្លួន ។ ជាក់ស្តែង កិច្ចខិតខំប្រឹងប្រែងនៃសមាជិកគណៈកម្មការបច្ចេកទេសទាំង៣ ខាងលើគឺត្រូវបានស្តែងចេញនូវលទ្ធផលផ្លែផ្កានាថ្ងៃនេះ ហើយសុំកោតសរសើរផងដែរ ដែលសមាជិកក្រុមប្រឹក្សាទាំងអស់ បានចូលរួមចំណែកជាច្រើន ក្នុងការផ្តល់មតិយោបល់ជួយកែតម្រូវ ពាក្យពេចន៍ ឃ្លាឃ្លោក ពាក្យបច្ចេកទេស និងពាក្យជាភាសារបរទេសជាដើម ធ្វើយ៉ាងណាឱ្យសេចក្តីព្រាងស្តង់ដារ ចំនួន០៨ ខាងលើ ទទួលបានធាតុចូលគ្រប់គ្រាន់ សម្រាប់ការពិចារណា និងអនុម័តដោយការទទួលខុសត្រូវខ្ពស់ ក្នុងន័យចូលរួមបម្រើផលប្រយោជន៍ជាតិ និងប្រជាជន សំដៅដល់កិច្ចការពារអ្នកប្រើប្រាស់ ធានាសុខភាពសាធារណៈ បរិស្ថាន និងសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្មជាតិ អន្តរជាតិ ។